- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** ត្រូវបានដំឡើងឋានន្តរស័ក្តិជូនមន្ត្រីរាជការ ចំនួន ០២ រូប ពីឋានន្តរស័ក្តិវរមន្ត្រី ទៅឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៃក្រសួងយុត្តិធម៌ ជាករណីពិសេស ៖

| ល.រ | គោត្តមនាម និង នាម | ភេទ | ក្របខ័ណ្ឌ ឋានន្តរស័ក្តិ និង ថ្នាក់ | |
|---|---|---|---|---|
| | | | ចាស់ | ស្នើសុំ |
| ១ | ចាន់ សុទ្ធារី | ស | ពីវរមន្ត្រី ថ្នាក់លេខ ១០ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ២ | ប៉ែន ពេជ្រសាលី | ប | ពីវរមន្ត្រី ថ្នាក់លេខ ១០ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៦ |

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

[illegible]

*ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១២*

លេខ: ៧២៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១២
អគ្គលេខាធិការរងនៃទីស្ដីការរាជរដ្ឋាភិបាល
សុយ សុខា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៣៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៥.៩០៨ ហិកតា ស្ថិតនៅក្នុងភូមិសាស្រ្ត ស្រុកសំរោង ខេត្តឧត្តរមានជ័យ

# រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-យោងតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# សម្រេច

**មាត្រា១:**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៥.៩០៨ (ប្រាំពាន់ប្រាំបួនរយប្រាំបី) ហិកតា ដែលមានទីតាំងស្ថិតនៅក្នុងឃុំកូនក្រៀល ស្រុកសំរោង ខេត្តឧត្តរមានជ័យ ដើម្បីធ្វើការវិនិយោគដាំដំណាំកសិ-ឧស្សាហកម្ម(អំពៅ) ដំណាំផ្សេងៗ និងសាងសង់រោងចក្រកែច្នៃស្ករអំពៅ ដូចមាននៅក្នុងផែនទី និងនិយាមការចុះថ្ងៃទី ២៨ ខែមករា ឆ្នាំ២០០៩ របស់អគ្គនាយកសុរិយោដី និងភូមិសាស្ត្រ ដែលភ្ជាប់ជាមួយនឹងលិខិតលេខ ៩០ជនស/អវទ ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ២០០៩ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា២:**

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគ ដូចកំណត់ក្នុងមាត្រា១ នៃអនុក្រឹត្យនេះត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្ត ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល។

**មាត្រា៣:**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤:**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គ្រប់ក្រសួងស្ថាប័ន និងអភិបាលខេត្តឧត្តរមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ២០១២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល:</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារកាលប្បវត្តិ

## ប្លង់បង្ហាញទីតាំងដីជាកម្មវត្ថុ នៃដីសម្បទានសេដ្ឋកិច្ច
## ស្ថិតនៅក្នុងឃុំសំរោង ស្រុកសំរោង ខេត្តឧត្តរមានជ័យ
## របស់ក្រុមហ៊ុន ខេមបូឌា ខេន អេន ស្វីញើរ ឌែវលើ

មាត្រដ្ឋាន : 1:70,000




| តារាងពិពណ៌នាការកំណត់ចំណុចទីតាំងដី | | |
|---|---|---|
| Projection UTM, zon 48 N Datum WGS 84 | | |
| ប្លុក B01 | | |
| ID | Northing | Easting |
| 1 | 1570324.376 | 347574.907 |
| 2 | 1570330.323 | 350207.568 |
| 3 | 1567723.636 | 349858.911 |
| 4 | 1568536.393 | 347575.789 |
| ប្លុក B02 | | |
| 5 | 1570331.071 | 350440.643 |
| 6 | 1570334.740 | 351582.300 |
| 7 | 1567924.742 | 351574.724 |
| 8 | 1567925.453 | 350457.088 |
| 9 | 1568991.119 | 350345.374 |
| 10 | 1568986.523 | 350168.215 |
| ប្លុក B03 | | |
| 11 | 1567556.743 | 351574.127 |
| 12 | 1564562.858 | 351586.496 |
| 13 | 1564530.210 | 351554.878 |
| 14 | 1564529.776 | 351253.545 |
| 15 | 1564542.439 | 350770.895 |
| 16 | 1564540.358 | 350085.435 |
| 17 | 1567682.371 | 350051.191 |
| ប្លុក B04 | | |
| 18 | 1567322.075 | 345574.789 |
| 19 | 1568323.436 | 347575.894 |
| 20 | 1568506.316 | 347575.804 |
| 21 | 1567854.383 | 349057.402 |
| 22 | 1566355.095 | 349056.670 |
| 23 | 1566696.446 | 348592.975 |
| 24 | 1564523.684 | 349844.554 |
| 25 | 1563543.586 | 345573.459 |
| 44 | 1567046.446 | 347614.975 |
| 45 | 1566904.447 | 346624.976 |
| 46 | 1565849.371 | 346592.343 |
| 47 | 1565243.446 | 348471.973 |
| 48 | 1564580.929 | 349820.014 |
| ប្លុក B05 | | |
| 26 | 1561585.000 | 345575.732 |
| 27 | 1563512.803 | 345573.472 |
| 28 | 1564495.249 | 349863.273 |
| 29 | 1561470.429 | 350847.011 |
| 30 | 1561581.000 | 349574.000 |
| 31 | 1561579.000 | 347574.000 |
| ប្លុក B06 | | |
| 32 | 1564575.456 | 356568.246 |
| 33 | 1559498.854 | 356576.235 |
| 34 | 1559364.955 | 354569.050 |
| 35 | 1560053.132 | 352574.655 |
| 36 | 1560313.736 | 351973.229 |
| 37 | 1560825.161 | 351979.506 |
| 38 | 1562609.184 | 352280.590 |
| 39 | 1563550.029 | 351666.780 |
| 40 | 1564097.555 | 352173.303 |
| 41 | 1563722.778 | 352466.297 |
| 42 | 1564545.897 | 352674.801 |
| 43 | 1564563.520 | 352719.160 |

**សញ្ញាសំគាល់**

- ដីជាកម្មវត្ថុ នៃដីសម្បទានសេដ្ឋកិច្ច
- ផ្លូវទទឹង ៣០ម៉ែត្រ
- ព្រែកទន្លេទទឹង ២០០ម៉ែត្រ

| ក្បាលដី | ទំហំ គិតជាហិកតា |
|---|---|
| B01 | 551.05 |
| B02 | 307.72 |
| B03 | 497.39 |
| B04 | 1,049.47 |
| B05 | 1,304.05 |
| B06 | 2,199.17 |
| សរុប | 5,908.86 |

**ផ្ទៃដីជាកម្មវត្ថុ នៃដីសម្បទានសេដ្ឋកិច្ច ក្រុមហ៊ុន ខេមបូឌា ខេន អេន ស្វីញើរ ឌែវលើ : ទំហំ ៥.៩០៨.៨៦ ហិកតា**

វាស់វែង និង គូរដោយ មន្ត្រីនាយកដ្ឋានបច្ចេកទេស នៃអគ្គនាយកដ្ឋានសុរិយោដី និង ភូមិសាស្ត្រ ឧបករណ៍វាស់វែង GPS ( Leica 500 )

ភ្នំពេញ,ថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០០៩
ប្រធានក្រុមវាស់វែង

ឈុម សោភ័ណ

បានឃើញ និង ឯកភាព
ភ្នំពេញ,ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០០៩
[illegible]យោដី និង ភូមិសាស្ត្រ

ឈឹម វ៉ាន់

បានពិនិត្យត្រឹមត្រូវ
ភ្នំពេញ,ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០០៩
ប្រធាននាយកដ្ឋានបច្ចេកទេស

ឡោ ជានុន

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៩៩៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ ._**

ត្រូវបានបំពាក់ **គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ** ផ្តល់ជូនសប្បុរសជន ចំនួន០២រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាង អគារសិក្សា០១ខ្នង មានចំនួន ០៥បន្ទប់ អាងស្តុកទឹកភ្លៀង ០១កន្លែង និងបង្គន់អនាម័យ ០១ខ្នង នៅ**វិទ្យាល័យព្រះនរោត្តមរណឫទ្ធិ** ស្ថិតនៅក្នុងស្រុកទឹកឈូ ខេត្តកំពត ដែលមានរាយនាមដូចខាងក្រោម :

១-**Mr. FRANCIS IAN MURRAY** សប្បុរសជននៅប្រទេសអូស្ត្រាលី ថវិកាចំនួន ២០.២០០ ដុល្លារ

២-**Mr. PAGET SAYES** សប្បុរសជននៅប្រទេសអូស្ត្រាលី ថវិកាចំនួន ១៩.០៦៤,៩០ ដុល្លារ

**មាត្រា ២ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលខេត្តកំពត និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៩៨៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.—**

ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ផ្តល់ជូនមន្ត្រីរាជការ និងមន្ត្រីនគរបាលជាតិ ចំនួន ៤៨ រូប ដែលបានលះបង់កំលាំងកាយចិត្តចូលរួមចំណែកជួយកសាង និងអភិវឌ្ឍន៍មូលដ្ឋានលើគ្រប់វិស័យ ស្ថិតនៅក្នុងឃុំបឹងព្រីង ស្រុកថ្មគោល ខេត្តបាត់ដំបង ដែលមានរាយនាមដូចខាងក្រោម ៖

**ក_ មេដាយមាសការងារចំនួន ២៣ គ្រឿង ផ្តល់ជូន ៖**

១-លោក **ឆាយ ទៀន** សមាជិកក្រុមប្រឹក្សាឃុំបឹងព្រីង ស្រុកថ្មគោល

២-លោកអនុសេនីយ៍ត្រី **ខ៉ាន គឿន** មេបញ្ជាការរងមូលដ្ឋានកងរាជអាវុធហត្ថស្រុកថ្មគោល

៣-លោក **អ៊ុំម គឹមស៊ុន** ស្មៀនឃុំបឹងព្រីង ស្រុកថ្មគោល

៤-លោក **លីក ផល្លា** អនុប្រធានការិយាល័យ នៃមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត

៥-លោកស្រី **លី គឹមជូ** ប្រធានការិយាល័យ នៃមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត

៦-លោក **សុខ សេរីវិជ្ជា** អនុប្រធានការិយាល័យនៃមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត

៧-លោកស្រី **ហេង សុនិនី** អនុប្រធានការិយាល័យ នៃមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត

៨-លោក **សុខ គុណា** នាយករងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ព្រៃកូនខ្លា ខេត្តបាត់ដំបង

៩-លោកស្រី **សុខ ម៉ុនឈាង** មន្ត្រី នៃវិទ្យាស្ថានបច្ចេកវិទ្យាបាត់ដំបង

១០-លោក **ម៉ន សាឌុន** មន្ត្រី នៃវិទ្យាស្ថានបច្ចេកវិទ្យាបាត់ដំបង

១១-លោក **ជឹម ចន្ថន** មន្ត្រី នៃវិទ្យាស្ថានបច្ចេកវិទ្យាបាត់ដំបង

១២- លោក **រី ទុឡើ** មន្ត្រី នៃវិទ្យាស្ថានពហុបច្ចេកទេសបាត់ដំបង

១៣-លោក **ឈន រ៉េត** មន្ត្រី នៃវិទ្យាស្ថានពហុបច្ចេកទេសបាត់ដំបង

១៤-លោកស្រី **ភាន សាមឺន** សប្បុរសជនរស់នៅខេត្តបាត់ដំបង

១៥-លោក **ឡាង មុត** សប្បុរសជនរស់នៅខេត្តបាត់ដំបង

១៦-លោកវរសេនីយ៍ត្រី **ជិន សគា** នាយការិយាល័យ នៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង

១៧-លោកវរសេនីយ៍ត្រី **ភុំ រីណូ** នាយការិយាល័យ នៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង

១៨-លោកវរសេនីយ៍ត្រី **ឡុង ទុទ្ធី** នាយរងការិយាល័យ នៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង

១៩-លោកវរសេនីយ៍ត្រី **ម៉ែន ខ្វយ** មន្ត្រី នៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង

២០-លោកពលបាលឯក **ពុជ ទុទ្ធី** មន្ត្រី នៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង

២១-លោកព្រិន្ទបាលទោ **ណូ ម៉ៃយ៉ា** មន្ត្រី នៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង

២២-លោកព្រិន្ទបាលទោ **ម៉ែន នេង** មន្ត្រី នៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង

២៣-លោកស្រី **ទៀង គីរ៉េត** សប្បុរសជនរស់នៅខេត្តបាត់ដំបង

**ខ. មេដាយប្រាក់ការងារចំនួន ១៤ គ្រឿង ផ្តល់ជូន :**

១-លោក **លឹម ស៊ីថន** ប្រធានការិយាល័យ នៃមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តបាត់ដំបង

២-លោកស្រី **ឈើត ដានី** អនុប្រធានការិយាល័យ នៃមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តបាត់ដំបង

៣-លោក **នី ចិត្រា** មន្ត្រី នៃមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តបាត់ដំបង

៤-លោក **ម៉ុយ ចាន់រ៉ុង** មន្ត្រី នៃមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តបាត់ដំបង

៥-លោក **អ៊ាប សុវណ្ណា** មន្ត្រី នៃមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តបាត់ដំបង

៦-លោក **ទុន សុឃីន** មន្ត្រី នៃមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តបាត់ដំបង

៧-លោកស្រី **ថ្វង សុគន្ធា** មន្ត្រី នៃមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តបាត់ដំបង

៨-លោក **ណក់ តក្តី** មន្ត្រីការិយាល័យបរិស្ថានស្រុកថ្មគោល

៩-លោកពលបាលឯក **ផល សៅលឹម** មន្ត្រីកងរាជអាវុធហត្ថស្រុកថ្មគោល

១០-លោកព្រិន្ទបាលឯក **សាម ដារ៉ា** មន្ត្រីកងរាជអាវុធហត្ថស្រុកថ្មគោល

១១-លោកព្រិន្ទបាលឯក **អ៊ុំ ស្រស់** មន្ត្រីកងរាជអាវុធហត្ថស្រុកថ្មគោល

១២-លោកព្រិន្ទបាកឯក **ហៀង ម៉ុនថន** មន្ត្រីកងរាជអាវុធហត្ថស្រុកថ្មគោល

១៣-លោកពលបាកឯក **ឈឿន ឌុច** មន្ត្រីកងរាជអាវុធហត្ថស្រុកថ្មគោល

១៤-លោក **ឡៅ គទី** មន្ត្រីកងរាជអាវុធហត្ថស្រុកថ្មគោល

**គ. មេដាយសំរិទ្ធិការងារចំនួន ១១ គ្រឿង ផ្តល់ជូន :**

១-លោកស្រី **ឃឹម លឿន** អនុប្រធានភូមិអូរញ ឃុំបឹងព្រីង ស្រុកថ្មគោល

២-លោកស្រី **ឡុញ អាំ** សប្បុរសជនរស់នៅខេត្តបាត់ដំបង

៣-លោក **ប៉ឿន ឡេន** សប្បុរសជនរស់នៅខេត្តបាត់ដំបង

៤-លោក **ឡឿន រដ្ឋា** សប្បុរសជនរស់នៅខេត្តបាត់ដំបង

៥-លោក **ឡឹន អាន** សប្បុរសជនរស់នៅខេត្តបាត់ដំបង

៦-លោក **ឡឹម យិញ** សប្បុរសជនរស់នៅខេត្តបាត់ដំបង

៧-លោក **ទឿន កុម្ភៈ** សប្បុរសជនរស់នៅខេត្តបាត់ដំបង

៨-លោក **ហែម សារុន** សប្បុរសជនរស់នៅខេត្តបាត់ដំបង

៩-លោក **ឡុង មុន្នី** សប្បុរសជនរស់នៅខេត្តបាត់ដំបង

១០-លោកស្រី **គង់ ឌុច** សប្បុរសជនរស់នៅខេត្តបាត់ដំបង

១១-លោកស្រី **អោគ សុទៀត** សប្បុរសជនរស់នៅខេត្តបាត់ដំបង

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលខេត្តបាត់ដំបង និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១២*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ: ៩៦៩. អនក្រ.បក**

# អនុក្រឹត្យ
# ស្តីពី
# ការតែងតាំងមន្ត្រីរាជការ

***៚***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## **សម្រេច**

**មាត្រា ១.-**

តែងតាំងមន្ត្រីរាជការនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចមានរាយនាមខាងក្រោម ÷

១. លោក **ម៉ែន សំអាន** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
២. លោក **នួន ចំនួនរិទ្ធ** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ អគ្គនាយក គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ សីហា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល*** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ដូចមាត្រា ២
- ឯកសារ- កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១០០០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.—**

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ផ្តល់ជូនសប្បុរសជន និងមន្ត្រីរាជការចំនួន ៣០ រូប ដែលបានលះបង់កំលាំងកាយចិត្តចូលរួមចំណែកជួយកសាង និងអភិវឌ្ឍន៍មូលដ្ឋានលើគ្រប់វិស័យ ស្ថិតនៅក្នុងឃុំបឹងព្រីង ស្រុកថ្មគោល ខេត្តបាត់ដំបង ដែលមានរាយនាមដូចខាងក្រោម៖

**ក. មេដាយមុនីសារាភ័ណ្ឌថ្នាក់ធិបឌិន្ទចំនួន ០៩ គ្រឿង ផ្តល់ជូន :**

១-លោក **សំបូរ ផុន** អនុប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្តបាត់ដំបង

២-លោកស្រី **ឈុន ធារិន** ប្រធានការិយាល័យ នៃមន្ទីរកិច្ចការនារីខេត្តបាត់ដំបង

៣-លោក **ឌុយ សិទ្ធ** ប្រធានការិយាល័យ នៃមន្ទីរកិច្ចការនារីខេត្តបាត់ដំបង

៤-លោកស្រី **អ៊ាន ណារឿង** ប្រធានការិយាល័យ នៃមន្ទីរកិច្ចការនារីខេត្តបាត់ដំបង

៥-លោកស្រី **នម ឆៀប** ប្រធានការិយាល័យ នៃមន្ទីរកិច្ចការនារីខេត្តបាត់ដំបង

៦-លោក **វង្ស នាន** អនុប្រធានស្នាក់ការពន្ធដារស្រុកថ្មគោល

៧-លោក **ថា ថៃ** មន្ត្រីការិយាល័យបរិស្ថានស្រុកថ្មគោល

៨-លោក **ហេង ចន្ថា** គ្រូបង្រៀនវិទ្យាល័យនេតយ៉ង់ ខេត្តបាត់ដំបង

៩-លោក **លី ឌីនូរ៉ី** នាយករដ្ឋបាលសាលាស្រុកថ្មគោល

**ខ. មេដាយមុនីសារាភ័ណ្ឌថ្នាក់សេនាចំនួន ០៦ គ្រឿង ផ្តល់ជូន :**

១-លោក **សុខ សេត** អនុប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តបាត់ដំបង

២-លោក **ពៅ សានិត** អនុប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តបាត់ដំបង

៣-លោក **លឹម ថែម** មេឃុំបឹងព្រីង ស្រុកថ្មគោល

៤-លោក **ម៉ាក្ស ម៉ិនថន** មេបញ្ជាការផ្នែកសឹករងស្រុកថ្មគោល

៥-លោក **ណក់ ស៊ីណុន** ប្រធានការិយាល័យរដ្ឋបាល-ហិរញ្ញវត្ថុសាលាស្រុកថ្មគោល

៦-លោកអនុសេនីយ៍ឯក **គឹម ទាសនា** មេបញ្ជាការកងរាជអាវុធហត្ថស្រុកថ្មគោល

**គ. មេដាយមុនីសារាភ័ណ្ឌថ្នាក់អស្សឫទ្ធិចំនួន១៥ គ្រឿង ផ្តល់ជូន :**

១-លោក **ឡៃ ផូ** ប្រធានការិយាល័យនៃមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តបាត់ដំបង

២-លោក **មាស ដារ៉ា** ប្រធានការិយាល័យនៃមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តបាត់ដំបង

៣-លោកស្រី **ជួន ចន្ធី** ប្រធានការិយាល័យសេដ្ឋកិច្ច និងសង្គមកិច្ច សាលាខេត្តបាត់ដំបង

៤- លោកស្រី **ជួន ម៉ាន់ដេត** នាយិកាវិទ្យាស្ថានពហុបច្ចេកទេស ខេត្តបាត់ដំបង

៥- លោក **អ៊ឹម មិត្ត** នាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ព្រៃកូនខ្លា ខេត្តបាត់ដំបង

៦-លោក **លន់ ម៉ា** នាយករងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ព្រៃកូនខ្លា ខេត្តបាត់ដំបង

៧- លោកស្រី **ជួន សុផុន** សមាជិកក្រុមប្រឹក្សាឃុំបឹងព្រីង ស្រុកថ្មគោល

៨- លោក **ម៉ិន ថា** សមាជិកក្រុមប្រឹក្សាឃុំបឹងព្រីង ស្រុកថ្មគោល

៩- លោក **ប៊ឹង សុខន** សមាជិកក្រុមប្រឹក្សាឃុំបឹងព្រីង ស្រុកថ្មគោល

១០- លោក **ប៊ិង សុផាត** សមាជិកក្រុមប្រឹក្សាឃុំបឹងព្រីង ស្រុកថ្មគោល

១១-លោក **ទៀន សូ** មេភូមិបឹងព្រីង ស្រុកថ្មគោល

១២-លោក **យាម នាម** មេភូមិប៉ោយតាសេក ស្រុកថ្មគោល

១៣-លោក **ស្ពាន់ សុភាព** មេភូមិស្ទួលកោង ស្រុកថ្មគោល

១៤-លោក **គៀង សាមីន** សប្បុរសជនរស់នៅខេត្តបាត់ដំបង

១៥-លោក **ជិន រៀម** មេភូមិអូរញ្ញូរ ឃុំបឹងព្រីង ស្រុកថ្មគោល

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលខេត្តបាត់ដំបង និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ២០១២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:១០០១...អនក្រ.បក**

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមុខតំណែងនាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៧ ស្តីពីការប្រែក្លាយសាលាភូមិន្ទនគរបាល ទៅជាបណ្ឌិត្យសភានគរបាលកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២៤១ អនក្រ បក ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១១ ស្តីពីការកំណត់លក្ខណសម្បត្តិ និងឋានៈគ្រូនគរបាលជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានតែងតាំងមុខតំណែងនាយនគរបាលជាតិជាន់ខ្ពស់ នៃបណ្ឌិត្យសភានគរបាលកម្ពុជា ក្រសួងមហាផ្ទៃ ៖

១- លោកឧត្តមសេនីយ៍ត្រី **គង់ ជាន** អត្តលេខ ០៤៣៩ អនុប្រធានមន្ទីរចាត់ការ ទៅជា ទៅជាគ្រូនគរបាលជាតិកម្រិតឧត្តមថ្នាក់លេខ២ មានឋានៈស្មើប្រធាននាយកដ្ឋាន ។

២- លោកឧត្តមសេនីយ៍ត្រី **ប្រាក់ ថា** អត្តលេខ ០៨០៤ នាយករងវិទ្យាស្ថានគ្រប់គ្រង និងបញ្ជាដឹកនាំ ទៅជាគ្រូនគរបាលជាតិកម្រិតឧត្តមថ្នាក់លេខ២ មានឋានៈស្មើប្រធាននាយកដ្ឋាន ។

៣- លោកឧត្តមសេនីយ៍ត្រី **ធឹម បុត្រ** អត្តលេខ ៥៥១៥៤ នាយករងវិទ្យាស្ថានពត៌មានវិទ្យា និងភាសាបរទេស ទៅជាគ្រូនគរបាលជាតិកម្រិតឧត្តមថ្នាក់លេខ២ មានឋានៈស្មើប្រធាននាយកដ្ឋាន ។

៤- លោកវរសេនីយ៍ឯក **ផន សុភា** អត្តលេខ ០៩៩០ នាយករងវិទ្យាស្ថានស្រាវជ្រាវវិទ្យាសាស្ត្រនគរបាល ទៅជាគ្រូនគរបាលជាតិកម្រិតឧត្តមថ្នាក់លេខ២ មានឋានៈស្មើប្រធាននាយកដ្ឋាន ។

៥- លោកវរសេនីយ៍ឯក **មុំ ណារ៉ែន** អត្តលេខ ៥៦៥០៨ នាយករងសាលាមធ្យមវិជ្ជាជីវៈនគរបាល ទៅជាគ្រូនគរបាលជាតិកម្រិតឧត្តមថ្នាក់លេខ២ មានឋានៈស្មើប្រធាននាយកដ្ឋាន ។

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី [illegible] ខែ សីហា ឆ្នាំ ២០១២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួលៈ
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ១០០៤ អនក្រ.បក**

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមុខតំណែងនាយនគរបាលជាតិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៧ ស្តីពីការប្រែក្លាយសាលាភូមិន្ទនគរបាល ទៅជាបណ្ឌិត្យសភានគរបាលកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា ១ :** ត្រូវបានតែងតាំងមុខតំណែងនាយនគរបាលជាតិជាន់ខ្ពស់ នៃបណ្ឌិត្យសភានគរបាលកម្ពុជា ក្រសួងមហាផ្ទៃ ៖

១- លោកឧត្តមសេនីយ៍ទោ **នេត ឌុន្នី** អត្តលេខ ០២៣០០ នាយកវិទ្យាស្ថានស្រាវជ្រាវវិទ្យាសាស្ត្រនគរបាល ទៅជាអនុប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា ។

២- លោកឧត្តមសេនីយ៍ត្រី **ឈៀង ភារម្យ** អត្តលេខ ៥៤៧០៨ នាយករងវិទ្យាស្ថានពត៌មានវិទ្យានិងភាសាបរទេស ទៅជានាយកវិទ្យាស្ថានស្រាវជ្រាវវិទ្យាសាស្ត្រនគរបាល ។

៣- លោកឧត្តមសេនីយ៍ត្រី **អ៊ុំ សំអូន** អត្តលេខ ០១២៤៩ នាយករងវិទ្យាស្ថានគ្រប់គ្រង និងបញ្ញាដឹកនាំ ទៅជានាយកវិទ្យាស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈនគរបាល ។

៤- លោកឧត្តមសេនីយ៍ត្រី **ហៀ រិទ្ធី** អត្តលេខ ៦៧០១០ អនុប្រធានមន្ទីរចាត់ការ ទៅជានាយកវិទ្យាស្ថានគ្រប់គ្រង និងបញ្ញាដឹកនាំ ។

៥- លោកវរសេនីយ៍ឯក **ទិញ ឡា** អត្តលេខ ៥៦៥០៨ នាយករងសាលាមធ្យមវិជ្ជាជីវៈនគរបាល ទៅជាគ្រូនគរបាលជាតិកម្រិតឧត្តមថ្នាក់លេខ២ មានឋានៈស្មើប្រធាននាយកដ្ឋាន ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១០០៣ . អនក្រ . បក

# អនុក្រឹត្យ

## ស្តីពី

## ការដំឡើងឋានន្តរស័ក្តិនាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១** : ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ៖

១- លោកវរសេនីយ៍ទោ **លឹម ហួរ** អត្តលេខ ១៧៤៥៦

២- លោកវរសេនីយ៍ទោ **ឈឹម ថាណាវណ្ណា** អត្តលេខ ០៤៩០១

៣- លោកវរសេនីយ៍ទោ **ឧង សុខា** អត្តលេខ ៦១៩៩២

៤- លោកវរសេនីយ៍ទោ **ឈិន ឌី** អត្តលេខ ៤៤៤៤០

| | | | |
|---|---|---|---|
| ៥- លោកវរសេនីយ៍ទោ | **អឿ សុភាព** | អត្តលេខ | ៥៨៧៩ |
| ៦- កញ្ញាវរសេនីយ៍ទោ | **ស្វាយ ស៊ីថា** | អត្តលេខ | ៥៨០៤៣ |
| ៧- លោកស្រីវរសេនីយ៍ទោ | **ប៉ុណ្ណា សំខាន់** | អត្តលេខ | ១២២៩៥ |
| ៨- លោកវរសេនីយ៍ទោ | **ប៉ោ លីណាង** | អត្តលេខ | ៥៦៦០៥ |
| ៩- លោកវរសេនីយ៍ទោ | **ស៊ិន សម្បត្តិ** | អត្តលេខ | ០៥០៥៦ |
| ១០- លោកវរសេនីយ៍ទោ | **ពៅ សុធារ៉ាន់** | អត្តលេខ | ៦៨៣០០ |
| ១១- លោកវរសេនីយ៍ទោ | **សូ សារ៉ាត់** | អត្តលេខ | ០៧២៥៤ |
| ១២- លោកវរសេនីយ៍ទោ | **ពាង ចាន់ថន** | អត្តលេខ | ៣១៤១៤ |
| ១៣- លោកវរសេនីយ៍ទោ | **ស៊ីម ឈាន់** | អត្តលេខ | ៥៥១៤៩ |
| ១៤- លោកវរសេនីយ៍ទោ | **នឹម កុមារ** | អត្តលេខ | ០៥៨១៤ ។ |

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធនិងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួលៈ
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១០០៨ អនក្រ.តត

# អនុក្រឹត្យ
# ស្តីពី
# ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាលឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ :** ត្រូវបានតែងតាំងលោក **សាន ស៊ានហូ** ជាទីប្រឹក្សាក្រសួងមហាផ្ទៃ មានឋានៈស្មើ **អគ្គនាយករង** ។

**មាត្រា២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័ន និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០១២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខៈ១០០៥.អនក្រ.បក**

## អនុក្រឹត្យ
## ស្តីពីការដំឡើងថ្នាក់ និងឋានន្តរស័ក្តិមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យ លេខ ៧០ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងព័ត៌មាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងព័ត៌មាន

## សម្រេច

**មាត្រា ១ :** ត្រូវបានដំឡើងថ្នាក់តាមកម្រិតសញ្ញាប័ត្រ និងដំឡើងឋានន្តរស័ក្តិ ស្របតាមឧបនិស្ស័យមុខតំណែង ជូនមន្ត្រីរាជការក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួងព័ត៌មាន ចំនួន ០៣ រូបៈ

| ល.រ | គោត្តមនាម និង នាម | ភេទ | ក្របខ័ណ្ឌ ឋានន្តរស័ក្តិ និង ថ្នាក់ | |
|---|---|---|---|---|
| | | | ចាស់ | ស្នើសុំ |
| **ក.ដំឡើងថ្នាក់:** | | | | |
| ១ | ពេញ យ៉ាត | ប | ពីវរមន្ត្រី ថ្នាក់លេខ ៦ | ទៅវរមន្ត្រី ថ្នាក់លេខ ៥ |
| ២ | គាម ម៉ារិទ្ធីយ៉ា | ប | ពីវរមន្ត្រី ថ្នាក់លេខ ៩ | ទៅវរមន្ត្រី ថ្នាក់លេខ ៨ |
| **ខ.ដំឡើងឋានន្តរស័ក្តិ:** | | | | |
| ១ | ប៉ែត ស្មើ | ប | ពីអនុមន្ត្រី ថ្នាក់លេខ ១១ | ទៅវរមន្ត្រី ថ្នាក់លេខ ១០ |

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែសីហា ឆ្នាំ ២០១២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១០០៦ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦នស.៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០២ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកិច្ចការនារី
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅរបស់ក្រសួងកិច្ចការនារី
- បានឃើញអនុក្រឹត្យលេខ ៥៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកិច្ចការនារី

### សម្រេច

**មាត្រា ១** : ត្រូវបានតែងតាំង លោកស្រី **ប៉ូអាន ស៊ីខុន្ថា** ជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី មានឋានៈស្មើ អគ្គនាយករង ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃ [illegible] ខែ [illegible] ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល ៖</u>
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ១០០៧-អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយ សហមេត្រី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់ គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.**

ត្រូវបានបំពាក់មេដាយ **សហមេត្រី** តាមលំដាប់ថ្នាក់ជូនថ្នាក់ដឹកនាំស្នងការដ្ឋាននគរបាលខេត្តទៀងយ៉ាង នៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម បានជួយឧបត្ថម្ភថវិកាចំនួន ២៥.០០០ ដុល្លារអាមេរិក (ម្ភៃប្រាំពាន់ ដុល្លារអាមេរិកគត់) សំរាប់ទិញរថយន្តចំនួន ០២ គ្រឿង ជូនស្នងការដ្ឋាននគរបាលខេត្តពោធិ៍សាត់ ដូចមានរាយនាមខាងក្រោម:

**ក - គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ ធិបឌិន្ទ**

- លោកឧត្តមសេនីយ៍ត្រី **Nguen Chi Phi** នាយកមន្ទីរនគរបាលខេត្តទៀងយ៉ាង

**ខ - គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ សេនា**

១ - លោកវរសេនីយ៍ឯកបំរុង **Nguen Thanh Hai** អនុប្រធានការិយាល័យកស្តភារ និងកសាងកម្លាំងនគរបាលខេត្តទៀងយ៉ាង

២ - លោកស្រីវរសេនីយ៍ឯកបំរុង **Dang Thi My Gung** អនុប្រធានការិយាល័យរដ្ឋបាលនគរបាលខេត្តទៀងយ៉ាង

**មាត្រា ២.**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១២*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល៖***

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ដូចមាត្រា១ និងមាត្រា២*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៧០ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការតែងតាំងមុខងារ នាយទាហាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ១៥៩ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីការបង្កើតអគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**ប្រការ១ :** ត្រូវបានតែងតាំងមុខងារ នាយទាហាននៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម ៖

១-វរសេនីយ៍ទោ **សុវត្ថិ សុក្រឹត្យា** អត្តលេខ ០១៩៧៥៣ ជានាយការិយាល័យអនុព័ន្ធយោធា និងជាទីប្រឹក្សា យោធាអមស្ថានទូត ព្រះរាជាណាចក្រកម្ពុជា ប្រចាំទីក្រុងវៀងច័ន្ទ សាធារណរដ្ឋប្រជាមានិតឡាវ ជំនួសលោក វរសេនីយ៍ឯក **អ៊ុន សុផាន់ណា** ដែលត្រូវចប់អាណត្តិ

២-វរសេនីយ៍ត្រី **ហ៊ួន ចំរើន** អត្តលេខ ១០០៧៩១ ជាជំនួយការរដ្ឋបាល និងបច្ចេកទេសការិយាល័យអនុព័ន្ធយោធា អមស្ថានទូត ព្រះរាជាណាចក្រកម្ពុជា ប្រចាំទីក្រុងកង់ប៉េរ៉ា ប្រទេសអូស្ត្រាលី ជំនួសលោក វរសេនីយ៍ទោ **ប៊ុន អេងពិសិដ្ឋ** ដែលត្រូវចប់អាណត្តិ

៣-វរសេនីយ៍ត្រី **ជៀម ទីតា** អត្តលេខ ១៥១៨៤៨ ជាជំនួយការរដ្ឋបាលនិងបច្ចេកទេសការិយាល័យអនុព័ន្ធយោធា អមស្ថានទូត ព្រះរាជាណាចក្រកម្ពុជា ប្រចាំទីក្រុងវៀងច័ន្ទ សាធារណរដ្ឋប្រជាមានិតឡាវ ជំនួសលោក វរសេនីយ៍ត្រី មាស រតនៈសោភ័ណ ដែលត្រូវចប់អាណត្តិ

៨-អនុសេនីយ៍ឯក សាយ សក្តិស៊ុវុទ្ធី អត្តលេខ ១៦៨៤៦៣ ជាជំនួយការរដ្ឋបាលនិងបច្ចេកទេស ការិយាល័យអនុព័ន្ធយោធា អមស្ថានទូត ព្រះរាជាណាចក្រកម្ពុជា ប្រចាំរដ្ឋធានីវ៉ាស៊ីនតោន សហរដ្ឋអាមេរិក ជំនួសលោក វរសេនីយ៍ទោ កេន កិត្យារដ្ឋ ដែលត្រូវចប់អាណត្តិ

**ប្រការ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធនិង បណ្តាសមាសភាពដូចក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

**ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល**
**Ministry of Industry, Mines and Energy**

លេខ: ៥៣៣៣ ឧ.ប.ផ-ក.ឧ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី២១ ខែសីហា ឆ្នាំ២០១២

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញលិខិតលេខ១៥៦៨ /១២ គ.វ.ក ចុះថ្ងៃទី២៧.០៧.២០១២ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន លី ស៊ីន (ខេមបូឌា) ហ្គាមេន ខមភេនី លីមីតធីត ចុះថ្ងៃទី០២.០៧.២០១២

## សម្រេច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន លី ស៊ីន (ខេមបូឌា) ហ្គាមេន ខមភេនី លីមីតធីត (LI XIN (CAMBODIA) GARMENT COMPANY LIMITED) តំណាងដោយ លោក NI JIANZHONG សញ្ជាតិចិន អាយុ៤៧ឆ្នាំ កាន់លិខិតឆ្លងដែនលេខ G40598657 ចុះថ្ងៃទី២៨.០១.២០១០ មានអាសយដ្ឋានបច្ចុប្បន្ន No.6, Jianye Road, Changshu, Jiangsu China 215500. ជាម្ចាស់ រោងចក្រធ្វើការ បង្កើតរោងចក្រលេមុខសញ្ញាដូចខាងក្រោម៖

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ស្តង់ដារអន្តរជាតិនៃសកម្មភាពសេដ្ឋកិច្ច ISIC Rev.4 Code** |
|---|---|
| សម្លៀកបំពាក់ | ១៤១០ |



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១ , ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax : 855-23-428263

**ផ្លាកឈ្មោះរោងចក្រ ៖** *" រោងចក្រកាត់ដេរសម្លៀកបំពាក់ លី ស៊ីន (ខេមបូឌា) ហ្គាមេន ខមភេនី លីមីតធីត "*

**ទីតាំងរោងចក្រ ៖** *" ផ្លូវជាតិលេខ៤ ភូមិវំងួល ឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ "*

**ប្រការ២:** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣:** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤:** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥:** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

**ប្រការ៦:** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

**ប្រការ៧:** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

**ប្រការ៨:** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩:** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៨៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

**ប្រការ១១:** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

**ប្រការ១២:** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣:** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

**ប្រការ១៤:** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តកំពង់ស្ពឺ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

**ប្រការ១៥:** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ស៊ុយ សែម**

**ចម្លងជូន:**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលាខេត្តកំពង់ស្ពឺ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy

លេខ ៨៣៤ ឧ.រ.ថ.-ក.ឧ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី២១ ខែសីហា ឆ្នាំ២០១២

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើ ច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-បានឃើញលិខិតលេខ១៩០៥ /៩៨ គ.វ.ក ចុះថ្ងៃទី២៧.០៨.១៩៩៨ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុនហ្វរធ្យូន ហ្គារម៉ិន & វូលែន នីតធីង ហ្វាក់ធរី ចុះថ្ងៃទី៣១.០៧.២០១២

## សម្រេច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន ហ្វរធ្យូន ហ្គារម៉ិន & វូលែន នីតធីង ហ្វាក់ធរី (FORTUNE GARMENT & WOOLEN KNITTING FACTORY LTD.) តំណាងដោយលោក ចេង ចាន់គង់ សញ្ជាតិខ្មែរ អាយុ៥៨ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ០១០៧០១៣២២ ចុះថ្ងៃទី០៧.០៧.២០០៨ មានអាសយដ្ឋានបច្ចុប្បន្នៈ ផ្ទះលេខ... ផ្លូវលេខ២ ភូមិព្រែកតាគង់ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញាដូចខាងក្រោម ៖

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| សម្លៀកបំពាក់(កាត់ដេរ និងចាក់) | ...៣០ |



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១ , ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh. Phone : 855-23-211141 . Fax : 855-23-428263

